archive.today
webpage capture
Saved from https://postnews.com.kh/business/297728 search
no other snapshots from this url
13 May 2022 02:37:04 UTC
All snapshots from host postnews.com.kh
Webpage Screenshot
share download .zip report bug or abuse donate



POST NEWS






LTD វិនិយោគ វៀតណាម អាមេរិក -

# រោងចក្រកែច្នៃផលជ័រកៅស៊ូ នៅខេត្តកំពង់ធំ បើកដំណើរការជាផ្លូវការ




ថ្ងៃអាទិត្យ, ទី28 ខែខែមករា, 2018 08:23 ព្រឹក 0 Comments

កាលពីពេលថ្មីៗនេះ រោងចក្រកែច្នៃផលជ័រកៅស៊ូរបស់ក្រុមហ៊ុន C.R.C.K 2 Aphivath Caoutchouc Co., Ltd ដែលមានទីតាំងនៅឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ បានបើកសម្ពោធឲ្យដំណើរការជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។

ក្នុងពិធីនេះដែរ ក៏មានការចូលរួមពីសំណាក់ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម សុខ លូ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ឯកឧត្តម Vu Quang Minh ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា រួមជាមួយឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ។

គិតមកទល់ដំណាច់ឆ្នាំ ២០១៧ រោងចក្រកែច្នៃផលជ័រកៅស៊ូរបស់ក្រុមហ៊ុន C.R.C.K 2 Aphivath Caoutchouc Co., Ltd បានធ្វើការដាំដុះលើផ្ទៃដីប្រមាណជា ១៦,២៦៩ហិកតា ដែលបានបោះទុនវិនិយោគអស់ថវិកាចំនួន ១២០ លានដុល្លារអាមេរិក។
នេះជាការវិនិយោគដំណាក់កាលទី១ របស់ក្រុមហ៊ុន សរុបជាង ១០លានដុល្លារអាមេរិក ដែលត្រូវកសាងរោងចក្រ និងឃ្លាំងស្តុកកៅស៊ូ លើផ្ទៃដីជាង ១០ហិកតា មានលទ្ធភាពផលិតជ័រកៅស៊ូជាង ២១,៥០០តោនក្នុង ១ឆ្នាំ។
គួរជម្រាបថា ក្រុមហ៊ុន មានផែនការពង្រីកការវិនិយោគដំណាក់កាល ទី២ ដែលនឹងមានលទ្ធភាពផលិតជ័រកៅស៊ូជាង ៤៥,០០០តោនក្នុង ១ឆ្នាំ ហើយបច្ចុប្បន្នបានបង្កើតការងារជូន ប្រជាពលរដ្ឋប្រមាណជា ២០០០នាក់៕

## Latest Post



### ក្មេងទំនើងជិះម៉ូតូ ដេញវាយគ្នានៅតាមដងផ្លូវជាតិលេខ២១ ពេលនេះជាប់ហើយ



### សមត្ថកិច្ចឃាត់មនុស្ស៧នាក់ករណីហិង្សាបណ្តាលឲ្យខូចខាតទ្រព្យសម្បត្តិ



### គ្រោះថ្នាក់ចរាចរណ៍! រវាងរថយន្តសាំយ៉ុងនិងម៉ូតូបុកគ្នា បណ្តាលឲ្យស្ត្រីម្នាក់ស្លាប់បាត់បង់ជីវិត







អ៊ំប្រុសមានវ័យចំណាស់ម្នាក់ បាន បាត់ខ្លួនពីរថ្ងៃមិនឃើញមកផ្ទះ បង ប្អូនប្រទះឃើញទាក់ទងលេខខាង ក្រោមនេះ!...



បុរសអ្នកដើរទិញអេតចាយម្នាក់ ជួបគ្រោះថ្នាក់ចរាចរណ៍ រថយន្តបុករ៉ឺម៉កម៉ូតូ បណ្ដាលឲ្យ ស្លាប់ចោលកូន និងប្រពន្ធកំពុង មានផ្ទៃពោះបីខែ



ជនសង្ស័យ៤នាក់ ជិះម៉ូតូធ្វើសកម្ម ភាពឆក់ទូរស័ព្ទ ត្រូវកម្លាំង សមត្ថកិច្ចឃាត់ខ្លួន៣នាក់



កម្លាំងចម្រុះខណ្ឌសែនសុខ បង្ក្រាប ក្រុមក្មេងទំនើង៧៣នាក់ មានដាវ និងកាំបិតប៉័ងតោពេលកំពុងផឹកស៊ី



ករណីគ្រោះថ្នាក់ចរាចរណ៍! រថយន្ត ពីរគ្រឿងបុកគ្នាពេញទំហឹង បណ្ដាលឲ្យរងការខូចខាតទាំង សងខាង



កម្លាំងនគរបាលខណ្ឌមានជ័យ ឃាត់ខ្លួនជនសង្ស័យ៣នាក់ ករណី គាស់ទ្វាររបងផ្ទះពលរដ្ឋយកម៉ូតូ








រថយន្តធុនធំពីរគ្រឿងបុកគ្នា បណ្តាលឲ្យមនុស្សពនាក់រងរបួស ត្រូវដឹកបញ្ជូនទៅកាន់មន្ទីរពេទ្យ



**មតិយោបល់**




អាសយដ្ឋានៈ ផ្ទះលេខ១៦ ស្តួន ផ្លូវលេខ៤១៩ ភូមិ២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

House: 16 Stuon, Street# 410, Phum 2,Sangkat Boeng trabaek ,Khan Chamkar Mon, Phnom Penh, CAMBODIA Tel: (855) 92 343 434

Apps

GET IT ON Google Play

Download on the App Store

Social

Post News Media

Post News TV

Post News Youtube

Post News twitter

Latest Post

Copyright © 2015 by PNM. All Rights Reserved.